**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា**
ការិយាល័យតំណាងក្រសួងពាណិជ្ជកម្មប្រចាំ
រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត អូរនាង

បន្ទាយមានជ័យ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ:** របាយការណ៍ស្តីពីស្ថានភាពរបស់តំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត អូរនាង(POSEZ)

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបថា:

បច្ចុប្បន្ន នៅក្នុងរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត-អូនាង(POSEZ) មានរោង ចក្រចំនួន ០៥ ដែលបានសុំការអនុញ្ញាតិពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) មានដូចខាងក្រោម:

I- រោងចក្រដែលកំពុងដំណើរការផលិត:

ក្រុមហ៊ុន ខេមផេក ខូអិលធីឌី CAMPACK Co., Ltd. ជារោងចក្រផលិត ប្រអប់វេចខ្ចប់គ្រឿងអលង្ការ។ បច្ចុប្បន្ន ការសាងសង់អគារសម្រាប់ពង្រីកសង្វាក់ផលិតកម្ម ដែលនឹងមានតម្រូវការកម្មករបន្ថែមប្រមាណជា៣០០នាក់ ត្រូវបានសាងសង់រួចរាល់។

II- រោងចក្រកំពុងដំណើរការសាងសង់:

ក្រុមហ៊ុន ហាយ-ថេក អឺភែរឺល (ខេមបូឌា) Hi-Tech Apparel (Cambodia) Co., Ltd ជារោងចក្រកាត់ដេរសម្លៀកបំពាក់កីឡា។ ជាក់ស្តែងដូចក្នុងដំណើរទស្សនកិច្ច របស់ប្រតិភូក្រសួងពាណិជ្ជកម្មទៅកាន់បណ្តាខេត្តតាមព្រំដែនកម្ពុជា-ថៃ នាថ្ងៃទី ១៦ ដល់ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៣ ដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី និងលោកជំទាវ កន្លង ទៅ រោងចក្រខាងលើនេះទើបសាងសង់បានប្រមាណជា៨០%ប៉ុណ្ណោះ។ ប៉ុន្តែ បច្ចុប្បន្ន តួអគាររោងចក្រត្រូវបានសាងសង់រួចរាល់ និងបានបំពាក់ម៉ាស៊ីន ព្រមទាំងកំពុងធ្វើការ ជ្រើសរើសកម្មករ ដើម្បីហ្វឹកហាត់ និងបម្រើការក្នុងរោងចក្រ។

III- រោងចក្រដែលចុះកិច្ចសន្យាសាងសង់:

ក្រុមហ៊ុន អឹម អិល អ៊ិនធឺមេត អឺភែរឺល (ខេមបូឌា) ML Intermate Apparel (Cambodia) Co., Ltd. បច្ចុប្បន្ន ក្រុមហ៊ុនខាងលើបានចុះកិច្ចសន្យាសាងសង់ ហើយបាននឹងកំពុងចាក់ដីពង្រាបទីតាំង ព្រមទាំងដាក់សម្ភារៈដើម្បីធ្វើការសាងសង់តួអគារ។

ទន្ទឹមនោះដែរ សាម៉ីក្រុមហ៊ុនម្ចាស់តំបន់ CHHAY CHHAY INVESTMENT Ltd. ក៏បានសាងសង់អគាររដ្ឋបាលរបស់ខ្លួនដែលមានទំហំប្រមាណជា៥០០ការ៉េដីរួចរាល់ហើយដែរ។

IV- ការចូលរួមពិនិត្យទីតាំងស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសរបស់ក្រុមហ៊ុន SANCO CAMBO INVESTMENT GROUP Co.,Ltd.

យោងលិខិតចាត់តាំងមន្ត្រីតំណាងក្រសួងពាណិជ្ជកម្មលេខ: 1223 ព.ណ បល ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០១៣។ នៅថ្ងៃទី០៤/០៤/២០១៣ ខ្ញុំបាទបានចូលរួមជាមួយ គណៈកម្មាការចម្រុះអន្តរក្រសួងពិនិត្យទីតាំងស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសរបស់ ក្រុមហ៊ុនខាងលើដែលមានទីតាំងស្ថិតនៅភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ លើទំហំផ្ទៃដី៦៦,៥០ហិតា។ ខ្ញុំបាទសូមជូនភ្ជាប់ ជាមួយនូវសេចក្តីសង្ខេបនៃគម្រោងស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសរបស់ក្រុមហ៊ុន SANCO CAMBO INVESTMENT GROUP Co.,Ltd. ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបជា របាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** ទទួលការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

មន្ត្រីតំណាងក្រសួងពាណិជ្ជកម្ម

**ឡុង សោភ័ណ**

**<u>ចម្លងជូន</u>**

-ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេស
-អគ្គនាយកដ្ឋានគយ និងរដ្ឋាករ
-អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
-អគ្គនាយកដ្ឋានកាំកុងត្រូល
-នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
-នាយកដ្ឋានពាណិជ្ជកម្មទ្វេភាគី
-នាយកដ្ឋានពាណិជ្ជកម្មពហុភាគី
-នាយកដ្ឋានស្ថិតិ និងព័ត៌មាន
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

នាយកដ្ឋានប្រតិបត្តិការ និង គ្រប់គ្រង

## សេចក្តីសង្ខេបនៃគម្រោងស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស

## របស់ក្រុមហ៊ុន SANCO CAMBO INVESTMENT GROUP CO., LTD.

**ឈ្មោះក្រុមហ៊ុន** : SANCO CAMBO INVESTMENT GROUP Co.,Ltd.

**គោលដៅវិនិយោគ** : បង្កើតតំបន់សេដ្ឋកិច្ចពិសេស

**ដើមទុនវិនិយោគ** : ៣៨.៦១៣.៤៨៥.00 ដុល្លារអាមេរិក ដែលក្នុងនោះ :

**ម្ចាស់ភាគហ៊ុន** : - លោក ឈូ វិចិត្រ ភាគហ៊ុនចំនួន ៥១%

- លោក Takahiro Yamamoto ភាគហ៊ុនចំនួន ៤៩%

**ទីតាំងវិនិយោគ** : ភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលវិនិយោគលើទំហំផ្ទៃដី **៦៦.៥០ ហិកតា** ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យត្រឹមត្រូវ និងមានការបញ្ជាក់ពីអាជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់ ។

**ការអនុវត្តន៍គម្រោង** : គម្រោងស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេសនេះ បានបែងចែកការអនុវត្តនីគម្រោងជាដំណាក់កាល ដូចខាងក្រោម :

- **ដំណាក់កាលទី ១ :** សិក្សាគម្រោង និងបួងលំអិតផ្សេងៗ (កុម្ភៈ ២០១៣ - កក្កដា ២០១៣)
- **ដំណាក់កាលទី ២ :** ការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ (សីហា ២០១៣ - កក្កដា ២០១៦) :
  - ការកសាងផ្លូវមេចូលក្នុងតំបន់ និងផ្លូវទទឹងក្នុងតំបន់ ដែលមានទំហំ ១៥ម៉ែត្រ — ២០ម៉ែត្រ និង២៥ម៉ែត្រ
  - ភ្ជាប់បណ្តាញអគ្គីសនីចូលក្នុងតំបន់ និងកសាងម៉ាស៊ីនផ្គត់ផ្គង់អគ្គីសនីដោយខ្លួនឯង

- ភ្ជាប់បណ្ដាញទឹកស្អាតនៅក្នុងតំបន់
- រៀបចំកសាងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- រៀបចំសួនច្បារ ទីលានកីឡាសំរាប់កម្មករ និងតំបន់បៃតង
- បង្កើតតំបន់ពាណិជ្ជកម្ម និងទីលំនៅដ្ឋានសំរាប់កម្មករ
- កសាងអាគារការិយាល័យនៃរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស និងការិយាល័យក្រុមហ៊ុន

**ការកសាងហេដ្ឋារចនាសម្ព័ន្ធ** : ក្រុមហ៊ុនមានគម្រោងធ្វើការបែងចែក សំរាប់បំរើឱ្យផ្នែកសំខាន់ៗ ដូចខាងក្រោម :

- ការិយាល័យរដ្ឋបាលតំបន់ និងក្រុមហ៊ុន
- តំបន់កែច្នៃនាំចេញ
- តំបន់ពាណិជ្ជកម្ម
- តំបន់លំនៅដ្ឋានសម្រាប់បុគ្គលិក-កម្មករ
- ផែស្ងួត
- ទីលានសាធារណៈ សួនច្បារ និងតំបន់បៃតង

**ប្រភពទឹកស្អាត និងអគ្គីសនី** : ដោយតំបន់នេះស្ថិតនៅក្នុងក្រុងប៉ោយប៉ែត ដែលមានលក្ខណៈងាយស្រួលក្នុងតភ្ជាប់ប្រភពទឹកស្អាត និងអគ្គីសនី សំរាប់ការប្រើប្រាស់នៅក្នុងតំបន់ ។ លើសពីនេះ ក្រុមហ៊ុន ក៏បានបម្រុងទុកក្នុងការផ្គត់ផ្គង់ទឹកស្អាត និងអគ្គីសនី ដោយខ្លួនឯង ដើម្បីស្របតាមតម្រូវការប្រើប្រាស់របស់អ្នកវិនិយោគនៅក្នុងតំបន់ ។

**ប្រភពធនធានមនុស្ស** : គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសនេះ មានភាពងាយស្រួលក្នុងការទាក់ទាញកម្លាំងពលកម្ម ជាពិសេស ក៏អាចមានលទ្ធភាពស្រូបយកមកវិញនូវកម្លាំងពលកម្មរបស់ពលករកម្ពុជា ដែលចូលទៅបំរើការងារនៅក្នុងប្រទេសថៃ ។



MAP LOCATION LAND AT PIOPET CITY (BMC PROVINCE)
N
W
E
S
MAP
SCALE=1:38000
LAND PIOPET
PROJECT
ACCESS ROAD
5
234000
236000
238000
240000
242000
244000
246000
248000
1508000
1510000
1512000
1514000
1516000
53
64
56
44
48
42
37
35
27
28